00242328

D97/4

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត

| | | |
|---|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស |
| កាលបរិច្ឆេទឯកសារ | ៖ | ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | ភាសាអង់គ្លេស |
| ប្រភេទឯកសារ | ៖ | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 11 / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Huy

# ពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្តីពីការបន្ថែមចំនួនទំព័រសម្រាប់ការសង្កេតរបស់ខ្លួន លើសហកម្មឧក្រិដ្ឋកម្មរួម អនុលោមតាម ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៨

| បញ្ជូនដោយ៖ | ចែកចាយជូន៖ | ចែកចាយជូន៖ |
|---|---|---|
| ការិយាល័យសហព្រះរាជអាជ្ញា៖ | សហចៅក្រមស៊ើបអង្កេត៖ | មេធាវីរបស់អ្នកដាក់ពាក្យសុំ |
| លោកស្រី ជា លាង | ចៅក្រម យូ ប៊ុនឡេង | អៀង សារី៖ |
| លោក Robert PETIT | ចៅក្រម Marcel LEMONDE | លោក អាង ឧត្តម |
| លោក យ៉េត ចរិយា | | លោក Michael KARNAVAS |
| លោក William SMITH | | មេធាវីរបស់ជនត្រូវចោទដទៃទៀត៖ |
| លោក តាន់ សេណារ៉ុង | | លោក សុន អរុណ |
| លោក Anees AHMED | | លោក Michiel PESTMAN |
| | | លោក Victor KOPPE |
| | | លោក ផាត់ ពៅស៊ាង |
| | | កញ្ញា Diana ELLIS |
| | | លោក សរ សុវាន |
| | | លោក Jacques VERGES |
| | | លោក ការ សាវុត្ថ |
| | | លោក François ROUX |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 11 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Huy

## សេចក្តីសន្និដ្ឋាន

១. នៅក្នុងញត្តិស្នើសុំ ("ញត្តិ") ដែលដាក់ជូនថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ជនត្រូវចោទ អៀង សារី ("អ្នកដាក់ពាក្យសុំ") បានប្រឆាំងនឹងការអនុវត្តន៍នូវទម្រង់នៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ដែលហៅថា សហកម្មឧក្រិដ្ឋកម្មរួម ("JCE") នៅចំពោះមុខតុលាការនេះ[1] ។ ដោយពិចារណាថា បញ្ហានៃសហកម្មឧក្រិដ្ឋកម្ម "ច្បាស់ណាស់ថាមានសារសំខាន់" ហើយ សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ ក៏បានបង្គាប់ដល់ភាគីនៅក្នុងករណី ឲ្យដាក់ការសង្កេតរបស់ខ្លួន ("ការសង្កេត") នៅលើបញ្ហានេះ ។ សំរាប់គោលបំណងនេះ សហចៅក្រមស៊ើបអង្កេតបានផ្តល់ការអនុញ្ញាតចំពោះថេរវេលាច្រើនជាងបីខែ ដើម្បីឲ្យគូភាគីអាចជួយសហចៅក្រមស៊ើបអង្កេតបង្កើតបាននូវ "សេចក្តីសម្រេចមួយ ដោយសារទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ"[2] ។

២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការដាក់កំហិតអំពីចំនួនទំព័រដោយឲ្យមានត្រឹមតែ១៥ទំព័រ ដូចដែលបានកំណត់នៅក្នុងសេចក្តីណែនាំអនុវត្តនោះ នឹងមិនគ្រប់គ្រាន់ឡើយ ដើម្បីឲ្យលើកឡើងលើគ្រប់ទិដ្ឋភាពទាំងអស់នៃបញ្ហាដ៏មានសារៈសំខាន់នេះ[3] ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យសហចៅក្រមស៊ើបអង្កេត បង្កើនចំនួនទំព័រដែលបានកំណត់ រហូតដល់សាមសិប (៣០)ទំព័រ ដើម្បីឲ្យគូភាគីអាចធ្វើសារណាល្មមគ្រប់គ្រាន់ ដល់ពួកគេ ។ សេចក្តីណែនាំអនុវត្ត អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត ធ្វើដូច្នេះបាននៅក្រោម "កាលៈទេសពិសេស"[4] ។ តាមការអនុវត្តន៍ជាក់ស្តែងលើ

---

[1] *ករណីរបស់ អៀង សារី* ពាក្យស្នើសុំរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហកម្មឧក្រិដ្ឋកម្មរួម ("JCE")*, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ចុះថ្ងៃទី២៨ កក្កដា ២០០៨, ERN 00208225-00208240, D97 (*ចាប់ពីនេះតទៅហៅថា* ញត្តិ) ។

[2] *ករណីរបស់ អៀង សារី* ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមានឈ្មោះថា *សហកម្មឧក្រិដ្ឋកម្មរួម*, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស, ចុះថ្ងៃទី១៦ កញ្ញា ២០០៨, ERN 00224208-00224209, D97/II, ទំព័រទី ២ (*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចស្តីពីការដាក់ឯកសារ) ។

[3] មាត្រា៥.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ច្បាប់ចេញលើកទី៣ ចុះថ្ងៃទី២៧ តុលា ២០០៨ (*ចាប់ពីនេះតទៅហៅថា* សេចក្តីណែនាំអនុវត្ត) ។

[4] មាត្រា៥.៤ នៃសេចក្តីណែនាំអនុវត្ត ។

ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ សារៈសំខាន់ដែលមានលក្ខណៈបញ្ចុះបញ្ចូលសំរាប់តុលាការនេះ ក៏គាំទ្រចំពោះការបង្កើនបែបនេះដែរ[5] ។

៣. លើសពីអ្វីៗទាំងអស់ កាលៈទេសៈលើកលែងនានាដែលធ្វើយុត្តិកម្មលើការបន្ថែមចំនួនទំព័រ ដែលត្រូវកម្រិត គឺ៖

i. សហចៅក្រមស៊ើបអង្កេត បានទទួលស្គាល់ថា បញ្ហាសហកម្មឧក្រិដ្ឋកម្មរួមគឺមាន “សារៈសំខាន់យ៉ាងជាក់ច្បាស់”[6] ។ តាមទស្សនៈនៃសារៈសំខាន់នេះ ពួកគេបានអនុញ្ញាតឲ្យភាគីនានា មានរយៈពេលវែងគ្រប់គ្រាន់សម្រាប់ការពិភាក្សាជញ្ជឹងគិត ក្នុងការដាក់សេចក្តីសង្កេតរបស់ខ្លួន ។ រយៈពេលចំនួន ៥ ខែ ចាប់ពីការដាក់សារណា គឺមានថេរៈវេលាវែងខុសពីធម្មតា បើប្រៀបធៀបទៅនឹងរយៈពេលចំនួន ១៥ ថ្ងៃ ដែលគេរំពឹងថានឹងត្រូវដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នានា នៅចំពោះមុខអង្គបុរេជំនុំជម្រះ[7] ។ បើសិនជាភាគីទាំងឡាយត្រូវបានអនុញ្ញាតឲ្យដាក់ចម្លើយតបដែលមានចំនួន ៣០ ទំព័រ ក្នុងរយៈពេល ១៥ ថ្ងៃ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដូច្នោះបើតាមការជាប់ទាក់ទងគ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវតែបន្ថែមចំនួនទំព័រដែលត្រូវកម្រិត នៅពេលដែលចម្លើយតបទាំងនោះត្រូវបានសុំឲ្យដាក់ បន្ទាប់ពីការពិភាក្សាជញ្ជឹងគិតដែលមានរយៈពេលចំនួន ៥ ខែ[8] ។

---

[5] *រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន,* សេចក្តីសម្រេចលើញត្តិស្នើសុំជាការប្រញាប់របស់អយ្យការ ដែលសុំបន្ថែមចំនួនទំព័រលើសចំនួនកំណត់សម្រាប់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន, សំណុំរឿងលេខ SCSL-2004-16-A ចុះថ្ងៃទី២៤ កញ្ញា ២០០៧, ត្រង់ទំព័រទី ២ ។ *រដ្ឋអាជ្ញា ទល់នឹង Seselj,* សេចក្តីសម្រេចលើសំណើរបស់អយ្យការដែលស្នើសុំបន្ថែមចំនួនទំព័រលើសពីចំនួន១០ទំព័រដែលបានកំណត់ សម្រាប់ញត្តិស្នើសុំផ្សេងៗរបស់ខ្លួន, សំណុំរឿងលេខ IT-03-67-PT, ចុះថ្ងៃទី៤ កុម្ភៈ ២០០៥, ត្រង់ទំព័រទី២ ។ *រដ្ឋអាជ្ញា ទល់នឹង Stanisic,* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីដែលស្នើបន្ថែមចំនួនទំព័រលើសពីចំនួនកំណត់ទាក់ទងទៅនឹងសារណាមុនពេលសវនាជំនុំជម្រះក្តី របស់មេធាវីការពារក្តី, សំណុំរឿងលេខ IT-03-69-PT, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី៦ ធ្នូ ២០០៤ ។ *រដ្ឋអាជ្ញា ទល់នឹង Milutinovic,* សេចក្តីសម្រេចលើសំណើរបស់អយ្យការ ដែលស្នើសុំបន្ថែមចំនួនទំព័រលើសពីចំនួនកំណត់, សំណុំរឿងលេខ IT-99-37-PT, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី៣ មិថុនា ២០០៤, ត្រង់ទំព័រទី ២ ។

[6] ដីកាសម្រេចស្តីពីការដាក់ឯកសារ, ទំព័រទី ២ ។

[7] សេចក្តីណែនាំអនុវត្ត, មាត្រា ៨.៣ ។

[8] សេចក្តីណែនាំអនុវត្ត, មាត្រា ៥.២ ។

ii. នៅក្នុងការពិចារណាលើបញ្ហាស្រដៀងគ្នានេះ អង្គបុរេជំនុំជម្រះ បានស្នើសុំសារណារបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ចំនួន ៣ ដែលសារណានីមួយៗត្រូវមានចំនួន ៣០ ទំព័រ[9] ។ ម៉្យាងវិញទៀត សហចៅក្រមស៊ើបអង្កេត ធ្លាប់បានបង្គាប់ឲ្យភាគីនានាដាក់តែសេចក្តីសង្កេតរបស់ខ្លួនប៉ុណ្ណោះ ។ ហេតុដូច្នេះ វាជាការសមស្របដែលថា ភាគីនានាត្រូវបានអនុញ្ញាតឲ្យដាក់សេចក្តីសង្កេតរបស់ពួកខ្លួន ដែលមានចំនួនទំព័រដូចគ្នានឹងចំនួនទំព័រសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដែរ ។ សហព្រះរាជអាជ្ញា កត់សម្គាល់ថា នៅពេលមានបញ្ហានានានៅចំពោះមុខអង្គបុរេជំនុំជម្រះ និងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មានលក្ខណៈស្រដៀងគ្នានោះ ក៏វាមិនជាន់គ្នាដែរ ព្រោះថា ដំណើរការនីតិវិធីទាំងពីរនេះ គឺចេញមកពីសំណុំរឿងផ្សេងគ្នា និងដែលមានភាគីផ្សេងពីគ្នា[10] ។

iii. ឥឡូវនេះ ក្នុងពេលដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការអញ្ជើញឲ្យគ្រប់ភាគីទាំងអស់ផ្តល់នូវសេចក្តីសង្កេតរបស់ខ្លួននោះ ក្នុងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា គឺចាំបាច់ត្រូវលើកឡើងអំពីភាពអាចអនុវត្តបាននូវសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងករណីរឿងរបស់បុគ្គលនីមួយៗក្នុងចំណោមជនត្រូវចោទទាំងប្រាំ(៥)រូប ដែលនៅក្នុងសំណុំរឿងនេះ ។ ដើម្បីនឹងធ្វើបែបនេះឲ្យបានត្រឹមត្រូវ ចំនួនទំព័រកំណត់តោងតែលើសពីដប់ប្រាំ(១៥)ទំព័រ ។ សហព្រះរាជអាជ្ញា កំពុងស្នើសុំឲ្យបានចំនួនទំព័រកំណត់ឲ្យបានសាមសិប(៣០)ទំព័រ ដែលចំនួននេះនៅតិចជាងចំនួនកំណត់ទំព័រដែលរួមបញ្ចូលគ្នាដែលមានដល់ទៅចិត្តសិបប្រាំ(៧៥)ទំព័រនោះឆ្ងាយណាស់ នេះគឺអនុវត្តចំពោះករណីថា បើសិនជាសហព្រះរាជអាជ្ញាត្រូវដាក់សារណាដាច់ដោយឡែកពីគ្នា ស្តីពីភាពអាចអនុវត្តបាននៃសហកម្មឧក្រិដ្ឋកម្មរួម ដែលទាក់ទងទៅនឹងជនត្រូវចោទទាំងប្រាំ(៥)រូបនេះ ។ ប្រសិនជាការស្នើសុំបន្ថែមចំនួន

---

[9] *ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច,* សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-០២), ចុះថ្ងៃទី២៣ កក្កដា ២០០៨, ERN 00225010-00225012, D97/3/12, ទំព័រទី ៣ ។ សេចក្តីអញ្ជើញស្រដៀងគ្នានេះចំនួនពីរ ត្រូវបានបង្គាប់ទៅអ្នកដែលមិនមែនជាភាគីនៃរឿងក្តីដទៃទៀត ។

[10] *ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច,* សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ *កាំង ហ្កេកអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-០២), ចុះថ្ងៃទី០៦ តុលា ២០០៨, ERN 00226067-00226070, D99/3/19, កថាខណ្ឌទី ១២ ។

ទំព័រ លើសពីដប់ប្រាំ(១៥)ទំព័រ មិនបានទទួលការអនុញ្ញាតយល់ព្រមទេនោះ សហព្រះរាជអាជ្ញា នឹងត្រូវកំរិតការសរសេរសេចក្តីសង្ខេបឲ្យប្រកបដោយប្រសិទ្ធិភាព ក្នុងចំនួនត្រឹមតែបី(៣)ទំព័រប៉ុណ្ណោះសម្រាប់ម្នាក់ៗវិញ ទោះបីជាជនត្រូវចោទនីមួយៗក្នុងចំណោម ជនត្រូវចោទទាំងនោះ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការស៊ើបសួរចំពោះឧក្រិដ្ឋកម្មមួយចំនួនក្នុងចំណោមឧក្រិដ្ឋកម្មដែលអាក្រក់ជាងគេបំផុតក្នុងសតវត្សរ៍ដែលកន្លងទៅ ដែលបានប្រព្រឹត្តជាផ្នែកនៅក្នុងពហុសហកម្មឧក្រិដ្ឋកម្មរួមមួយ ដែលបានរីករាលដាលនៅក្នុងទូទាំងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលក្នុងអម្លុងពេលជិត៤ឆ្នាំនោះក្តី ។

iv. បញ្ហាស្តីពីសហកម្មឧក្រិដ្ឋកម្មរួម គឺច្បាស់ណាស់ថា វាមានលក្ខណៈស្មុគ្រស្មាញ និងដែលតម្រូវឲ្យធ្វើការវិភាគមួយទៅលើបញ្ញត្តិនានានៃច្បាប់ និងយុត្តិសាស្ត្រតាំងពីសង្គ្រាមលោកលើកទី២ មក ។ ការវិភាគនេះក៏នឹងត្រូវរួមបញ្ចូលផងដែរ នូវការពិនិត្យមើលជារួមទៅលើច្បាប់របស់កម្ពុជានៅក្នុងរយៈពេលប្រាំមួយ(៦)ឆ្នាំកន្លងទៅនេះ ។ ជាងនេះទៅទៀត ដោយសារតែមានការសរសេរជាច្រើនស្តីពីបញ្ហានេះ ការពិនិត្យមើលជារួមទៅលើការសរសេររបស់អ្នកសិក្សាស្រាវជ្រាវនានា ក៏ចាំបាច់ត្រូវតែបានចូលជាផ្នែកនៅក្នុងសារណានេះដែរ ដើម្បីអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតអាចធ្វើ "សេចក្តីសម្រេចមួយបាន ដោយសារទទួលបានពត៌មានគ្រប់ជ្រុងជ្រោយ"[11] ។

v. ភាពដែលអាចអនុវត្តបាននៃសហកម្មឧក្រិដ្ឋកម្មរួមនៅចំពោះមុខតុលាការនេះ គឺច្បាស់ណាស់ថា វាគឺជាបញ្ហាខាងយុត្តាធិការដ៏ស្មុគ្រស្មាញមួយ ។ ការសម្រេចណាមួយលើបញ្ហានេះ គឺមានសក្តានុពលដែលធ្វើឲ្យមិនអាចក្តាប់បាននូវឧក្រិដ្ឋភាពទាំងអស់ ឬ ថែមទាំងអាចឈានទៅដល់ការលើកលែងការចោទប្រកាន់ ចំពោះជនទាំងឡាយដែលត្រូវបានចោទប្រកាន់ថាត្រូវទទួលខុសត្រូវ ចំពោះអំពើរំលោភបំពានផ្សេងៗដែលមានលក្ខណៈអាក្រក់ជាងគេបំផុតទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិនានា កាលពីក្នុងសតវត្សរ៍ដែលកន្លងទៅនេះទៀតផង ។ នេះគឺជាការច្បាស់លាស់ណាស់ថាមានភាពស្មុគ្រស្មាញ និងជាបញ្ហាដែលមានលាយបញ្ចូលគ្នានូវអង្គហេតុ ហើយនិងអង្គច្បាប់ ។ បញ្ហានេះតម្រូវឲ្យមាន

[11] ដីកាសម្រេចស្តីពីការដាក់ឯកសារ, ទំព័រទី ២ ។

ការព្យាបាលឲ្យបានត្រឹមត្រូវ និងយ៉ាងពេញលេញ ។ អាស្រ័យហេតុនេះ ការបន្ថែមចំនួនទំព័រលើសពីចំនួនដែលបានកំណត់ គឺត្រូវបានធ្វើយុត្តិកម្ម ។

**សំណើ**

៤. សហព្រះរាជអាជ្ញា សូមស្នើទៅសហចៅក្រមស៊ើបអង្កេត ដើម្បីសុំបន្ថែមចំនួនទំព័រពីលើចំនួនដែលកំណត់នៅក្នុងការដាក់សេចក្ដីសង្កេតរបស់ខ្លួន រហូតដល់ ៣០ទំព័រ ។ ការបន្ថែមនេះនឹងមិនធ្វើឲ្យមានការខូចខាតណាមួយផ្នែកសម្ភារៈ ដល់សិទ្ធិរបស់ជនត្រូវចោទដែលជាអ្នកដាក់ពាក្យសុំនោះទេ និងដើម្បីជាផលប្រយោជន៍ដល់យុត្តិធម៌[12] ។

៥. បើសិនជាការបន្ថែមទំព័រដូចដែលបានស្នើសុំនេះ ត្រូវបានអនុញ្ញាត សហព្រះរាជអាជ្ញា និងមិនមានការយល់ទាស់ទេ ចំពោះការបន្ថែមចំនួនទំព័រពីលើចំនួនកំណត់ណាមួយដែលមានលក្ខណៈត្រឹមត្រូវដល់ជនត្រូវចោទដែលជាអ្នកដាក់ពាក្យសុំ ប្រសិនបើជននេះមានបំណងចង់ធ្វើការឆ្លើយតបទៅនឹងសេចក្ដីសង្កេតរបស់ភាគីនានា ៕

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** — សហព្រះរាជអាជ្ញា

**លោក** William SMITH — សហព្រះរាជអាជ្ញារង

[12] *ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Brdjanin,* សេចក្ដីសម្រេចលើសំណើរបស់អយ្យការដែលស្នើសុំបន្ថែមចំនួនទំព័រពីលើសពីចំនួនដែលកំណត់នៅលើចម្លើយតប 98Bis, សំណុំរឿងលេខ IT-99-36-T, អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY, ចុះថ្ងៃទី៥ កញ្ញា ២០០៣, ទំព័រទី ១ ។